**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ.៤៤៣/២៣..ក. ស. ភ.

ថ្ងៃសុក្រ ៨រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព. ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលមហាសន្និបាតភាគហ៊ុនិកលើកទី ៨
# របស់កំពង់ផែស្វយ័តភ្នំពេញ

**កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)** មានកិត្តិយសសូមគោរពជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០ នាទីព្រឹក នៅចំណតផែកុងតឺន័រ LM១៧ របស់ ក. ស. ភ. បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៨ ក្រោមអធិបតីភាព **ឯកឧត្តម ហ៊ី បាវី** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយក ក. ស. ភ. និងជាប្រធានមហាសន្និបាត, **ឯកឧត្តម កែន សម្បត្តិ** សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ. និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **ឯកឧត្តម សួន រចនា** សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ. និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ព្រមទាំងមានការចូលរួមពីភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ភាគហ៊ុនិក និងថ្នាក់ដឹកនាំ ក. ស. ភ. ផងដែរ។ មហាសន្និបាតភាគហ៊ុនិកលើកទី៨ ប្រព្រឹត្តទៅយ៉ាងរលូន ដោយមានភាគហ៊ុនវត្តមានចំនួន **១៩.២៨៥.៥៩៨ ភាគហ៊ុន** ស្មើនឹង **៩៣,២%** នៃចំនួនភាគហ៊ុនសរុប និងទទួលបានលទ្ធផលដូចខាងក្រោម :

**១.** បានទទួលជ្រាបអំពីលទ្ធផលអាជីវកម្ម/សេវាកម្ម និងហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣

**២.** បានអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២២ ដោយក្នុងនោះ :
ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសរុប (Total Dividend per Share) : ២២៣,៨៣ រៀល
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសម្រាប់ភាគហ៊ុនិកប្រភេទ "ក" : ៣៤៥,៦០ រៀល
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសម្រាប់ភាគហ៊ុនិកប្រភេទ "ខ" : ១៩៣,៣៨ រៀល

**៣.** បានធ្វើការអនុម័តកញ្ចប់ប្រាក់លាភការក្រុមប្រឹក្សាភិបាលសម្រាប់ឆ្នាំ២០២៣ និងសម្រាប់ឆ្នាំបន្តបន្ទាប់រហូតដល់បញ្ចប់អាណត្តិទី៨ ចំនួន ១.១៥២.០០០.០០០រៀល/ឆ្នាំ។

អង្គមហាសន្និបាតភាគហ៊ុនិកលើកទី៨ បានបញ្ចប់នៅវេលាម៉ោង ១២:០០ នាទី នៅថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងការទទួលខុសត្រូវខ្ពស់។

**កំពង់ផែស្វយ័តភ្នំពេញ**

PHNOM PENH AUTONOMOUS PORT

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តីវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh